# កិច្ចព្រមព្រៀងស្តីពីគណនីមានកំរិតនៃកម្មវិធី CALFRESH

## ចំណុចសំខាន់ដែលត្រូវដឹង

**គណនីមានកំរិតគឺជា ៖**

គណនីមួយនៅក្នុងធនាគារ, សហជីពឥណទាន, ជាដើម ដែលគ្រួសារទទួលជំនួយពីកម្មវិធី CalFresh អាចទុកប្រាក់របស់គេសំរាប់ការចំណាយនានាខាងក្រោមដែលគេ អនុញ្ញាត ៖

- ទិញផ្ទះសំរាប់រស់នៅ;
- ចាប់ផ្តើមមុខរបរអាជីវកម្ម; ឬ
- ការអប់រំ ឬហ្វឹកហ្វឺនការងារសំរាប់ម្ចាស់គណនី និងអ្នកនៅក្រោមបន្ទុករបស់គេ (ច្រើន) ។ (អ្នកនៅក្រោមបន្ទុកគឺជនទាំងឡាយណាដែលគេអាចទាមទារថាជាអ្នកក្រោមបន្ទុកនៅក្នុងពន្ធចំណូលសហព័ន្ធរបស់ម្ចាស់គណនី ។)

មុនពេលបើកគណនីមានកំរិត អ្នកប្រហែលអាចត្រូវមានប្រាក់ សុទ្ធ និងធនធានផ្សេងៗទៀត (ដូចជាគណនីធនាគារ, ភាគហ៊ុន, អចលនវត្ថុ, ជាដើម) មិនលើសពីធនធានកំរិតរបស់អ្នកដែលមានសំរាប់ការប្រើប្រាស់របស់អ្នក ។ នេះជាមូលហេតុ ៖

**<u>បើអ្នកប្រើថវិកាអ្វីមួយនៅក្នុងគណនីមានកំរិតរបស់អ្នក (ច្រើន) សំរាប់បង់ថ្លៃភាពបន្ទាន់អាសន្ន ទោះបីជាភាពអាសន្ននោះដល់ថ្នាក់ជាមរណៈភាព ឬស្ថានភាពគំរាមកំហែងជីវិតក៏ដោយ ការដកនោះនឹងត្រូវរាប់បញ្ចូលទៅក្នុងធនធានកំរិតនៃចំនួន $2,000 ឬ $3,250 (បើសិនជាយ៉ាងហោចណាស់ មានមនុស្សម្នាក់ក្នុងក្រុមគ្រួសារជាអ្នកពិការ ឬអាយុ 60 ឆ្នាំ ឬចាស់) ។</u>**

**វិធាននានាសំរាប់គណនីមានកំរិត ៖**

- អ្នកត្រូវតែទទួលជំនួយពីកម្មវិធី CalFresh នៅពេលដែលអ្នកមកបើកគណនី ។
- គណនីមានកំរិតលើសពីមួយត្រូវបានអនុញ្ញាត ។
- មិនមានការកំរិតនៅលើចំនួនអតិបរមានៃការសន្សំក្នុងគណនីមានកំរិត ។
- ថវិកានៅក្នុងគណនីមានកំរិតទាំងអស់មិនត្រូវបានរាប់ប្រឆាំងនិងធនធានកំរិតរបស់គ្រួសារអ្នកទេ ។
- អ្នកត្រូវតែចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីគណនីមានកំរិត មុនពេលគណនីនោះចាត់ទុកថាជាគណនីមានកំរិត ។
- អ្នកអាចចំណាយបានតែថវិកាដែលអនុញ្ញាតឲ្យចំណាយតែប៉ុណ្ណោះ ។
- អ្នកត្រូវតែរក្សាថវិកា និងការប្រាក់នានាដែលបានមកពីគណនីមានកំរិត(ច្រើន) ដាច់ដោយឡែក ពីគណនីនានាផ្សេងទៀត ។
- ការប្រាក់រកបានពីគណនីមានកំរិត (ច្រើន) ត្រូវតែដាក់កក់ដោយផ្ទាល់ទៅក្នុងគណនី (ច្រើន) ។
- អ្នកត្រូវតែបញ្ចប់កិច្ចព្រមព្រៀងស្តីពីគណនីមានកំរិតសំរាប់គណនីមានកំរិតនិមួយៗ ។
- បើសិនជាអ្នកមានគណនីមានកំរិតមួយ ហើយអ្នកលែងទទួលជំនួយពីកម្មវិធី CalFresh ថវិកានោះប្រហែលជាត្រូវរាប់ប្រឆាំងនិងទ្រព្យរបស់អ្នក និងធនធាននានា បើសិនជាអ្នកដាក់ពាក្យសុំសំរាប់ជំនួយឡើងវិញ ។

## របាយការណ៍នៃការដកប្រាក់

- **ក្រុមគ្រួសារត្រូវរាយការណ៍ពាក់កណ្ដាលឆ្នាំ**
    - ការដកថវិកាក្នុងរយៈពេលពាក់កណ្ដាលឆ្នាំ មិនចាំបាច់ត្រូវតែរាយការណ៍រហូតដល់ពេលត្រូវរាយការណ៍ប្រាក់ចំណូលលើកក្រោយ (SAR 7) ឬពេលត្រូវធ្វើការបញ្ជាក់ឡើងវិញ ។
    - ខោនធីនឹងវាយតំលៃធនធាននានារបស់អ្នកជាមួយនឹងការទទួលរបាយការណ៍ពាក់កណ្ដាលឆ្នាំហើយនឹងធ្វើសេចក្ដីសំរេច បើការដកនោះគឺសំរាប់ការចំណាយដែលអនុញ្ញាតឬយ៉ាងណា ។ បើសិនជាធនធាននានារបស់អ្នកនៅក្រោមធនធានកំរិត ($2,000/$3,250), អ្នកនៅតែមានលក្ខណសម្បត្តិសំរាប់ជំនួយ បើពុំនោះទេមានលក្ខណសម្បត្តិទទួល ។
- **របាយការណ៍ការប្រែប្រួលរបស់ក្រុមគ្រួសារ**
    - ការដកប្រាក់ចេញពីគណនីមានកំរិតរបស់អ្នកត្រូវតែរាយការណ៍ក្នុងរវាង 10 ថ្ងៃ ចាប់ពីថ្ងៃបានដកថវិកានោះ ។
    - ខោនធីនឹងពិនិត្យមើលធនធានកំរិតក្នុងរវាង 10 ថ្ងៃ ចាប់ពីថ្ងៃដែលបានរាយការណ៍ ។
    - មូលហេតុនៃការដកប្រាក់នឹងកំណត់ពីការបន្តលក្ខណសម្បត្តិរបស់អ្នក ។
    - បើសិនជាធនធាននានារបស់អ្នកនៅក្រោមធនធានកំរិត ($2,000/$3,250) អ្នកនឹងនៅតែមានលក្ខណសម្បត្តិបន្ត ទទួលជំនួយទៀត ។

## ការចំណាយនានា

- **ទិញផ្ទះសំរាប់រស់នៅ ៖**

    អ្នកអាចចំណាយថវិកាក្នុងគណនីមានកំរិត លើ ៖

    - ការដាក់ប្រាក់កក់, ថ្លៃឈ្នួលផ្សេងៗ, បង់រំលស់, បង់សំរាប់ប្រាក់ដើម
    - ថ្លៃសំរាប់បញ្ចប់កម្ចី
    - ជួសជុល និងចលនវត្ថុតាំងភ្ជាប់នានា

    អ្នកមិនអាចចំណាយថវិកាក្នុងគណនីមានកំរិត លើ ៖

    - ទិញគ្រឿងសង្ហារឹម
    - របស់របរសំរាប់ផ្ទះ
- **ការអប់រំ ឬការហ្វឹកហ្វឺនការងារសំរាប់ម្ចាស់គណនី (ច្រើន) និងអ្នកនៅក្រោមបន្ទុក (ច្រើន) របស់គាត់ ៖**

    អ្នកអាចចំណាយថវិកាពីគណនីមានកំរិត លើ ៖

    - ថ្លៃឈ្នួលផ្សេងៗ, ថ្លៃសាលា, សៀវភៅ, គ្រឿងបរិក្ខារសាលា, សម្ភារៈនានា, សំលៀកបំពាក់ពិសេសដែលត្រូវការ
    - លំនៅដ្ឋានសិស្ស និងអាហារ
    - ថ្លៃដឹកនាំទៅមកពីសាលា/ការហ្វឹកហ្វឺនការងារ
    - សេវាមើលថែទាំកុមារព្រោះត្រូវការចូលសាលារៀន

## ការចំណាយ បន្ត ៖

- **ចាប់ផ្ដើមប្រកបអាជីវកម្មថ្មីមួយ ៖**

    អ្នកអាចចំណាយថវិកាក្នុងគណនីមានកំរិត លើ ៖

    - ការទិញ, ជួសជុល, និងការថែរក្សាសម្ភារៈសំរាប់អាជីវកម្ម
    - ឧបករណ៍, សំលៀកបំពាក់, គ្រឿងការពារ ឬសំលៀកបំពាក់តំរូវនានា និងស្បែកជើង
    - ប្រាក់បង់សងកម្ចី សំរាប់ប្រាក់ដើម និងការប្រាក់សំរាប់ទ្រព្យសកម្មអាជីវកម្ម ឬរបស់របរប្រើប្រាស់
    - ថ្លៃឈ្នួល និងថ្លៃទឹកភ្លើងផ្សេងៗសំរាប់ការិយាល័យ ឬជាន់ដែលជួល ។
    - ប្រាក់បៀវត្សរ៍និយោជិក
    - បញ្ជីសារពើភ័ណ្ឌ, ការបញ្ជូនទំនិញ, និងថ្លៃផ្ញើ
    - ថ្លៃអាជីវកម្ម, ពន្ធដារ, ការធានារ៉ាប់រង, ការចុះបញ្ជីគណនេយ្យ ឬសេវាសំរាប់អ្នកមានអាជីពនានា

    អ្នកមិនអាចចំណាយថវិកាក្នុងគណនីមានកំរិត លើ ៖

    - ការចំណាយផ្ទាល់ខ្លួន ដូចជាការកំសាន្ត

## ភ័ស្តុតាង

អ្នកត្រូវតែផ្ដល់ភ័ស្តុតាងទៅឲ្យខោនធីពេលណាបើកគណនីមានកំរិត និងដកថវិកាចេញពីគណនីមានកំរិត (ច្រើន) ។

- **ឧទាហរណ៍ខ្លះៗនៃការបង្កើត និង/ឬដកថវិកាចេញ មានដូចខាងក្រោម ៖**
    - សៀវភៅប្រាក់បញ្ញើ, របាយការណ៍ធនាគារ, ឬបង្កាន់ដៃពីធនាគារ, សហជីពឥណទាន ជាដើម ដែលបង្ហាញឈ្មោះ និងអាសយដ្ឋានរបស់ធនាគារ និងឈ្មោះនៅលើគណនី, លេខគណនី(ច្រើន) និង
    - រាល់គណនីសមតុល្យ និងសកម្មភាពតាំងពីកាលបរិច្ឆេទអ្នកបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្ដីពីគណនីមានកំរិត
- **ឧទាហរណ៍ខ្លះៗនៃភ័ស្តុតាងបង្ហាញពីរបៀបអ្នកបានចំណាយថវិកា មាន ៖**
    - សែកដែលបានលុបចោល
    - សេចក្ដីថ្លែងការណ៍ (ច្រើន) មានចុះហត្ថលេខាពីអ្នកផ្ដល់ការបំរើ (ច្រើន) ជារបស់របរ ឬសេវា ដែលមានបង្ហាញនូវប្រភេទ និងចំនួននៃការចំណាយ (ច្រើន) ដែលបានបង់ប្រាក់
    - បង្កាន់ដៃ
    - របាយការណ៍សមតុល្យស្ដីពីគណនីមានកំរិត